00767043

E159/Corr-1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សំណើសុំការកែតម្រូវ

**សំណុំរឿងលេខ៖** 002/19-09-2007-ECCC/TC

| កែលើឯកសារលេខ៖ | ERN(s): | កាលបរិច្ឆេទ៖ | ប្រភេទកំណែ៖ |
|---|---|---|---|
| E159 | 00766718-00766726 (Public) | 13 Jan 2012 | ☒ កែលើឯកសារដើម<br>☐ កែលើឯកសារបកប្រែ<br>☐ រៀបចំចាត់ថ្នាក់ឡើងវិញ |

| មូលហេតុនៃការកែតម្រូវ៖ |
|---|
| កែប្រែកថាខណ្ឌទី ៧ នៅទំព័រទី ៤ |

| សេចក្ដីលម្អិតនៃការកែតម្រូវ៖ |
|---|
| សូមមើលឯកសារដែលមាន Track Change. |

ស្នើដោយ៖ T-C                                        ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម)៖                 ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ)៖          ហត្ថលេខា៖

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 13 / 01 / 2012
ម៉ោង (Time/Heure) : 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

00767044

E159/Corr-1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង**

**កាលបរិច្ឆេទ: ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២**

**ជូនចំពោះ:** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រមទាំងអស់ និងមន្ត្រីច្បាប់ជាន់ខ្ពស់ នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **ការកំណត់កាលបរិច្ឆេទនៃសវនាការផ្ទាល់មាត់លើឯកសារនានា (ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២)**

១. កាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ កន្លងទៅ អង្គជំនុំជម្រះបានបង្គាប់ភាគីឲ្យបញ្ជាក់ឲ្យបានត្រឹមថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ថាតើនៅក្នុងបញ្ជីឯកសារមុនរបស់ខ្លួនដែលបានដាក់ដោយអនុលោមតាមសេចក្ដីបង្គាប់ E9 របស់អង្គជំនុំជម្រះ មានឯកសារណាខ្លះ ដែលខ្លួនមានបំណងដាក់មកអង្គជំនុំជម្រះ ក្នុងអំឡុងពេលសវនាការវគ្គដំបូងៗ[1]។ ភាគីទាំងអស់បានដាក់បញ្ជីឯកសារកែសម្រួលថ្មីរបស់ខ្លួនរួចរាល់អស់ហើយ លើកលែងតែមេធាវីការពារក្ដីជនជាប់ចោទ នួន ជា ប៉ុណ្ណោះ[2]។ ដោយអនុលោមតាមសេចក្ដីបង្គាប់មុនៗរបស់ខ្លួន អង្គជំនុំជម្រះកត់

[1] ប្រតិចារឹកនៃសវនាការបឋម ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E1/4.1 ទំព័រ ២៥។

[2] បញ្ជីឯកសាររបស់ ខៀវ សំផន សម្រាប់សវនាការដំណាក់កាលទីមួយ ឯកសារ E109/1 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ បញ្ជីឯកសាររបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់សវនាការបួនវគ្គដំបូង ឯកសារ E109/2 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីឯកសារ ដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងអំឡុងពេលសវនាការដំណាក់កាលទីមួយ ឯកសារ E109/4 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ បញ្ជីឯកសាររបស់ អៀង សារី សម្រាប់សវនាការបួនវគ្គដំបូង ឯកសារ E109/6 ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ

សម្គាល់ឃើញថា បញ្ជីឯកសារកែសម្រួលថ្មីទាំងនេះ ត្រូវលើកឡើងតែអំពីឯកសារនានានៅក្នុងបញ្ជីមុនរបស់ភាគីដែលភាគីយល់ថា ពាក់ព័ន្ធនឹងចំណុចអង្គហេតុ ដែលត្រូវជំនុំជម្រះដំណាក់កាលដំបូងនេះប៉ុណ្ណោះ។ ផ្ទុយទៅវិញ ឯកសារនានានៅក្នុងបញ្ជីកែសម្រួលថ្មីនេះ ដែលជាឯកសារបន្ថែមពីលើឯកសារដែលបានដាក់បញ្ចូលទៅក្នុងបញ្ជីមុនរបស់ភាគី ត្រូវបំពេញលក្ខខណ្ឌសម្រាប់ការទទួលយកឯកសារ ដែលពុំអាចរកបាននៅមុនពេលការចាប់ផ្ដើមជំនុំជម្រះ ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (ពាក់ព័ន្ធនឹងឯកសារថ្មី) និងយុត្តិសាស្ត្រមុនរបស់អង្គជំនុំជម្រះសាលាដំបូង (ពាក់ព័ន្ធនឹងឯកសារដែលមានរួចហើយនៅក្នុងសំណុំរឿង)[3]។

២. អង្គជំនុំជម្រះបង្គាប់ឲ្យភាគីបញ្ជាក់ឲ្យបានត្រឹមថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២ ថាតើឯកសារណាខ្លះដែលខ្លួនចង់ឲ្យភាគីបដិបក្ខទទួលយក ទាក់ទិននឹងចំណុចអង្គហេតុទាំង៤ ដែលត្រូវជំនុំជម្រះនៅសវនាការដំណាក់កាលដំបូង រងការជំទាស់ និងមូលដ្ឋាននៃការជំទាស់ទាំងនេះ (ឯកសារ E131/1)។ អង្គជំនុំជម្រះបានស្នើឲ្យភាគី "បញ្ជាក់ត្រួសៗពាក់ព័ន្ធនឹងឯកសារ ឬវត្ថុតាងនីមួយៗ ឬប្រភេទនៃឯកសារ ឬវត្ថុតាងដែលត្រូវបានជំទាស់ និងសេចក្ដីជំទាស់ដែលបានលើកឡើង"។ ក្រុមមេធាវីការពារក្ដីចំនួន៣ក្រុម បានដាក់សេចក្ដីជំទាស់របស់ខ្លួននៅក្នុងអំឡុងពេលវេលាផុតកំណត់នេះ (ឯកសារ E131/1/10 ឯកសារ E131/1/11 និងឯកសារ E131/1/12)។ អង្គជំនុំជម្រះនឹងពុំអនុញ្ញាតឲ្យភាគីធ្វើសារណាតបជាលាយលក្ខណ៍អក្សរ ទៅនឹងឯកសារទាំងនេះឡើយ

---

២០១១។ កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ កន្លងទៅ អង្គជំនុំជម្រះបានបង្គាប់ភាគីឲ្យបញ្ជាក់ឲ្យ បានត្រឹមថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ថាតើនៅក្នុងបញ្ជីឯកសារមុនរបស់ខ្លួន ឯកសារណាខ្លះដែលខ្លួនមានបំណងដាក់មកអង្គជំនុំជម្រះក្នុងអំឡុងពេលសវនាការរយៈពេល៣សប្ដាហ៍ដំបូង។ ភាគីទាំងអស់បានដាក់បញ្ជីឯកសារកែសម្រួលថ្មីរបស់ខ្លួនរួចរាល់អស់ហើយ លើកលែងតែមេធាវីការពារក្ដីជនជាប់ចោទ នួន ជា ប៉ុណ្ណោះ។ បញ្ជីឯកសារកែប្រែទាំងនេះ ក៏ត្រូវបានអង្គជំនុំជម្រះយកមកពិចារណាផងដែរ។

[3] *សូមមើល* សេចក្ដីសម្រេចស្ដីពីភាពអាចទទួលយកសម្ភារៈ ដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង, ឯកសារ E43/4, ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៩, កថាខណ្ឌ ៧ (ដែលបានបញ្ជាក់ថា ដើម្បីអាចយកមកប្រើប្រាស់ជាភស្តុតាងបាន សម្ភារៈដែលមាននៅក្នុងសំណុំរឿងត្រូវបំពេញឲ្យបាននូវបទដ្ឋានអប្បបរមានៃភាពជាប់ពាក់ព័ន្ធនិងភាពគួរឲ្យជឿជាក់បាន ប៉ុន្តែនៅពេលសម្ភារៈត្រូវបានដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ តម្លៃជាភស្តុតាង និងទម្ងន់នៃភស្តុតាង នឹងត្រូវស្ថិតក្រោមការវាយតម្លៃរបស់អង្គជំនុំជម្រះ)។

00767046

ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងធ្លាប់បានបញ្ជាក់ថាខ្លួននឹង "ផ្តល់ឱកាសឲ្យភាគីលើកទឡ្ហីករណ៍តទល់នៅក្នុងសវនាការ នៅក្នុងករណីចាំបាច់" (ឯកសារ E131/1)។

៣. ដូចបានបញ្ជាក់ជូនភាគីក្នុងអំឡុងកិច្ចប្រជុំរៀបចំសវនាការក្រៅផ្លូវការ កាលពីថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១២ កន្លងមកថ្មីៗ អង្គជំនុំជម្រះសាលាដំបូងនឹងយកថ្ងៃច័ន្ទ ទី ១៦ ខែ មករា ឆ្នាំ ២០១២ ដល់ថ្ងៃ ព្រហស្បតិ៍ ទី ១៩ ខែ មករា ឆ្នាំ ២០១២ សម្រាប់ធ្វើការពិចារណានៅតុលាការលើបញ្ហាឯកសារមួយចំនួនដូចខាងក្រោម៖

*ចម្លើយតបដោយផ្ទាល់មាត់ទៅនឹងសេចក្តីជំទាស់ ដោយអនុលោមតាមសេចក្តីបង្គាប់ E131/1*

៤. អនុលោមតាមឯកសារ E131/1 អង្គជំនុំជម្រះនឹងផ្តល់ឱកាសឲ្យភាគីឆ្លើយតបដោយផ្ទាល់មាត់ទៅនឹងសេចក្តីជំទាស់ខាងលើ ដែលខ្លួនបានទទួលក្នុងអំឡុងពេលផុតកំណត់ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២ ជំនួសឲ្យការឆ្លើយតបជាលាយលក្ខណ៍អក្សរ។ សេចក្តីលម្អិតបន្ថែមពាក់ព័ន្ធនឹងការទុកពេលវេលាសម្រាប់ការលើកទឡ្ហីករណ៍ផ្ទាល់មាត់ និងចម្លើយតបពាក់ព័ន្ធនឹងប្រភេទផ្សេងៗនៃឯកសារមានដូចខាងក្រោម។ បន្ទាប់ពីមានចម្លើយតបទាំងនេះ អង្គជំនុំជម្រះនឹងផ្តល់សិទ្ធិទៅក្រុមមេធាវីការពារក្តីនីមួយៗ ដើម្បីឆ្លើយតបទៅនឹងចម្លើយតប។

*ការលើកទឡ្ហីករណ៍ផ្ទាល់មាត់ស្តីពីការជំទាស់ទាន់ពេលវេលាទៅនឹងឯកសារ ដែលបានទទួលការដាក់ចំណាត់ថ្នាក់ E3 ជាបណ្តោះអាសន្ន*

៥. កាលពីថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ ដើម្បីអនុញ្ញាតឲ្យសវនាការលើសាក្សីដំបូង អាចដំណើរការទៅបាន ឯកសារទាំងអស់ដែលត្រូវបានលើកឡើងនៅត្រង់ជើងទំព័រនៃកថាខណ្ឌនានាពាក់ព័ន្ធប្រវត្តិ (*សូមមើល* E141) ត្រូវបានផ្តល់ចំណាត់ថ្នាក់ E3 និងត្រូវបានអង្គជំនុំជម្រះចាត់ទុកថាភាគីបានដាក់ចំពោះមុខខ្លួនរួចហើយ។ ដោយហេតុថា សេចក្តីជំទាស់ត្រូវបានដាក់នៅពេលក្រោយមកទៀតនៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១ (ឯកសារ E156) និងនៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២ (ឯកសារ E131/1/10 ឯកសារE131/1/11 និងឯកសារ E131/1/12) អង្គជំនុំជម្រះបានចាត់ទុកការដាក់ចំណាត់ថ្នាក់ E3 ផ្អែកលើមូលដ្ឋានពិសេស និងការទទួលយកឯកសារចំនួន ១២៥ ដូចដែលបានលើកឡើងខាងលើ ថាមានលក្ខណៈបណ្តោះអាសន្ន។ សេចក្តីជំទាស់

00767047

ដែលខ្លួនបានទទួលពាក់ព័ន្ធនឹងឯកសារចំនួនទាំង ១២៥ នេះ នៅក្នុងឯកសារ E156 និងឯកសារពាក់ព័ន្ធផ្សេងៗដែលបានលើកដោយមានភាពជាក់លាក់គ្រប់គ្រាន់ ត្រូវបានអង្គជំនុំជម្រះពិនិត្យមើលឡើងវិញ ចាប់តាំងពីពេលនោះ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ភាគច្រើននៃការជំទាស់ទាំងនេះគឺពាក់ព័ន្ធទៅនឹងថាតើប្រភេទទាំងអស់នៃឯកសារគួរត្រូវដាក់ជូនអង្គជំនុំជម្រះដែរឬទេ ដោយអនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

៦. ដូចប្រធានអង្គជំនុំជម្រះបានកត់សម្គាល់នៅក្នុងការសម្រេចផ្ទាល់មាត់កាលពីថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១២ កន្លងផុតទៅថ្មីៗ ដោយអនុលោមតាមវិធាន ៨៧(១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិទូលំទូលាយ ក្នុងការទទួលយកឯកសារនៅចំពោះមុខខ្លួន។ ជាទូទៅ អង្គជំនុំជម្រះអាចទទួលយករាល់ភស្តុតាងពាក់ព័ន្ធទាំងអស់ ទោះបីភស្តុតាងទាំងនោះរងការជំទាស់ក៏ដោយ ហើយនឹងពិចារណាលើការជំទាស់ទាំងនេះ នៅពេលវាយតម្លៃអំពីទម្ងន់នៃភស្តុតាង។ អង្គជំនុំជម្រះសូមធ្វើការកត់សម្គាល់ទៀតថា សារណា E158 របស់សហព្រះរាជអាជ្ញាដែលបញ្ជាក់អំពីភាពជឿជាក់ទៅលើយថាភាពនៃឯកភាព ត្រូវកំហិតត្រឹមឯកសារទាំងឡាយណា ឬប្រភេទឯកសារដែលខ្វះភាពជឿជាក់ ឬខ្វះភាពពាក់ព័ន្ធជាក់ស្តែងនៅក្នុងសារណារបស់មេធាវីការពារក្តីប៉ុណ្ណោះ ដោយអនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ ថ្វីត្បិតអង្គជំនុំជម្រះសាលាដំបូងយល់ថា ការដាក់ឯកសាររបស់ភាគី មានសារៈប្រយោជន៍ក្នុងការកំណត់បញ្ហាខ្វែងគំនិតគ្នានៅសវនាការក៏ដោយ ក៏ខ្លួននឹងមិនសម្រេចជាស្ថាពរស្តីពីយថាភាព ឬភាពអាចទុកចិត្តបាននៃឯកសារភាគច្រើន ដែលភាគីពុំទាន់បានដាក់មកអង្គជំនុំជម្រះឡើយ ដោយអនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ ថ្វីបើដូច្នេះ អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ថា ការជំទាស់ណាមួយដែលមេធាវីការពារក្តីបានលើកឡើងនឹងត្រូវអង្គជំនុំជម្រះសាលាដំបូងយកទៅថ្លឹងថ្លែងនៅពេលពិចារណាលើភស្តុតាងទាំងមូលនៅចុងបញ្ចប់នៃសវនាការ។

៧. ក្នុងក្របខ័ណ្ឌរួមនេះ <u>នៅថ្ងៃ ច័ន្ទ ទី ១៦ ខែ មករា ឆ្នាំ ២០១២</u> អង្គជំនុំជម្រះ<u>នឹងទុកពេលវេលាចំនួន៣០នាទី សម្រាប់ភាគីនីមួយៗលើកអំពីបញ្ហាភស្តុតាងទូទៅ ដែលត្រូវបានលើកឡើងដោយឯកសារពាក់ព័ន្ធនឹងសវនាការនេះ។ បន្ទាប់មក អង្គជំនុំជម្រះនឹងទុកពេលចំនួន ៩០នាទី</u>

សម្រាប់មេធាវីការពារក្តីលើកសេចក្តីជំទាស់ទៅនឹងឯកសារទាំងឡាយ ដែលអង្គជំនុំជម្រះសាលាដំបូងបានដាក់ចំណាត់ថ្នាក់ E3 រួចហើយ ( ដោយក្រុមមេធាវីនីមួយៗ មានពេលចំនួន ៣០ នាទី លើកលែងតែមានការឯកភាពផ្ទុយពីនេះពីសំណាក់ក្រុមមេធាវីការពារក្តីទាំងអស់)។ បន្ទាប់មកទៀត អង្គជំនុំជម្រះទុកពេលចំនួន ១ម៉ោងសម្រាប់សហព្រះរាជអាជ្ញា និង១៥នាទីសម្រាប់សហមេធាវីនាំមុខដើម្បីធ្វើការឆ្លើយតប។ អង្គជំនុំជម្រះនឹងទុករយៈពេលចំនួន ១៥ នាទីសម្រាប់ក្រុមមេធាវីការពារក្តីទាំងអស់ ដើម្បីធ្វើការឆ្លើយតបវិញដោយសង្ខេប។

Deleted: សូមយកថ្ងៃច័ន្ទ ទី ១៦ ខែ មករា ឆ្នាំ ២០១២ សម្រាប់ធ្វើ សវនាការលើការ

Deleted: បណ្តោះអាសន្ន

Deleted: ។ មេធាវីការពារក្តី មានពេលចំនួន ២ ម៉ោង សម្រាប់កិច្ចការនេះ (ដោយក្រុមនីមួយៗមានពេលចំនួន ៤០ នាទី លើកលែងតែមានការឯកភាពផ្ទុយពីនេះពីសំណាក់ក្រុមមេធាវីការពារក្តីទាំងអស់)។ បន្ទាប់មក សហព្រះរាជអាជ្ញានឹងមានរយៈពេលចំនួន ៩០ នាទី ហើយសហមេធាវីនាំមុខមានរយៈពេលចំនួន ៣០ នាទីដើម្បីឆ្លើយតប។

Deleted: ៣០

Deleted: ដល់

*ការជូនដំណឹងដល់ភាគីអំពីប្រភេទឯកសារ ដែលនឹងត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងឱកាសនៃការជំទាស់ផ្ទាល់មាត់ និងការឆ្លើយតប*

៨. ភាគីត្រូវបានណែនាំបន្ថែមទៀតថា អង្គជំនុំជម្រះមានបំណងដាក់ឯកសារនៃរយៈកាលកម្ពុជាប្រជាធិបតេយ្យគ្រប់ប្រភេទទាំងអស់ដូចតទៅនេះ នៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ ឯកសារដែលមានលេខសម្គាល់ផ្តើមដោយអក្សរ A ខាងក្រោមគឺជាលេខឯកសារយោងទៅនឹងឧបសម្ព័ន្ធនានានៃបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០១១ (E9/31) កន្លងមក ដោយសហព្រះរាជអាជ្ញាបានបញ្ជាក់រួចហើយ ថាជាឯកសារពាក់ព័ន្ធទៅនឹងដំណាក់ដំបូងនៃសវនាការ នៅក្នុងបញ្ជីឯកសារជាបន្តបន្ទាប់នៃឧបសម្ព័ន្ធរបស់ខ្លួន ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ (E109/4)។

A1 – សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ៖ ឯកសារទាំងអស់មាននៅក្នុងឯកសារ E9/31.1 ត្រូវបានបញ្ជាក់ថាមានពាក់ព័ន្ធក្នុងឯកសារ E109/4.1 (233 ឯកសារ);

A2 – អត្ថបទបោះពុម្ពផ្សាយ និងសេចក្តីណែនាំរបស់ ប.ក.ក៖ ឯកសារទាំងអស់មាននៅក្នុងឯកសារ E9/31.2 រៀបរាប់ថាមានពាក់ព័ន្ធក្នុងឯកសារ E109/4.2 (86 ឯកសារ);

A3 – កំណត់ហេតុអង្គប្រជុំរបស់ ប.ក.ក៖ ឯកសារទាំងអស់មាននៅក្នុងឯកសារ E9/31.3 រៀបរាប់ថាមានពាក់ព័ន្ធក្នុងឯកសារ E109/4.3 (58 ឯកសារ);

A4 – ឯកសារទំនាក់ទំនងកម្ពុជាប្រជាធិបតេយ្យ – ឯកសារទាំងអស់មាននៅក្នុងឯកសារ E9/31.4 រៀបរាប់ថាមានពាក់ព័ន្ធក្នុងឯកសារ E109/4.4 (394 ឯកសារ);

A5 – សារព័ត៌មានកម្ពុជាប្រជាធិបតេយ្យ & សេចក្តីថ្លែងការណ៍ជាសាធារណៈ៖ ឯកសារទាំងអស់មាននៅក្នុងឯកសារ E9/31.5 រៀបរាប់ថាមានពាក់ព័ន្ធក្នុងឯកសារ E109/4.5 (343 ឯកសារ);

A6 – ប្រវត្តិរូបកម្ពុជាប្រជាធិបតេយ្យ – ឯកសារទាំងអស់មាននៅក្នុងឯកសារE9/31.6 រៀបរាប់ថាមានពាក់ព័ន្ធក្នុងឯកសារ E109/4.6 (41 ឯកសារ);

A7 – បញ្ជីឯកសារពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិបតេយ្យ៖ឯកសារទាំងអស់មាននៅក្នុងឯកសារE9/31.7 រៀបរាប់ថាមានពាក់ព័ន្ធក្នុងឯកសារ E109/4.7 (169 ឯកសារ);

A8 – សេចក្តីថ្លែងការណ៍ផ្សេងៗទាក់ទងនឹងស្រុកត្រាំកក់៖ ឯកសារទាំងអស់មាននៅក្នុងឯកសារ E9/31.8 រៀបរាប់ថាមានពាក់ព័ន្ធក្នុងឯកសារ E109/4.8 (57 ឯកសារ);

A9 – កំណត់ត្រាអ្នកជាប់ឃុំនៅ សម២១៖ ឯកសារទាំងអស់មាននៅក្នុងឯកសារ E9/31.9 រៀបរាប់ថាមានពាក់ព័ន្ធក្នុងឯកសារ E109/4.9 (297 ឯកសារ);

A10 – ចម្លើយសារភាពមន្ទីរ សម២១៖ ឯកសារទាំងអស់មាននៅក្នុងឯកសារ E9/31.10 រៀបរាប់ថាមានពាក់ព័ន្ធក្នុងឯកសារ E109/4.10 (345 ឯកសារ)។

គ្រប់ឯកសារនៅក្នុងប្រភេទដូចបានរៀបរាប់ខាងលើនេះ មិនទាន់ត្រូវបានជំទាស់ នៅក្នុងអំឡុងពេលកាលបរិច្ឆេទផុតកំណត់ដែលអាចអនុវត្តបាន ត្រូវដាក់ជូនអង្គជំនុំជម្រះ។ ពាក់ព័ន្ធជាមួយឯកសារទាំងនោះ ឬប្រភេទនៃឯកសារដែលភាគីបានជំទាស់ អង្គជំនុំជម្រះបានរៀបចំទុកពេលវេលា គឺពីថ្ងៃអង្គារ៍ ទី ១៧ រហូតដល់ថ្ងៃ ព្រហស្បតិ៍ ទី ១៩ ខែ មករា ឆ្នាំ ២០១២ សម្រាប់ការពិភាក្សាផ្ទាល់មាត់ស្តីពីការជំទាស់ ចំពោះប្រភេទឯកសារ/ឯកសារខាងលើ ដែលមាននៅក្នុងឧបសម្ព័ន្ធ A1, A2, A3, A4 និង A5។

ការជំទាស់ ដែលមិនបានដាក់ជូនអង្គជំនុំជម្រះពីពេលមុន អនុលោមតាមសេចក្តីណែនាំមុនៗនោះគឺមិនអនុញ្ញាតទេ លុះត្រាតែមានការបង្ហាញពីករណីលើកលែង និងមូលហេតុសមស្រប។ ប៉ុន្តែ មេធាវីការពារក្តី អាចប្រើប្រាស់សវនាការនេះ ដើម្បីកំណត់នូវលក្ខណៈពិសេសដ៏សំខាន់របស់ឯកសារ ឬប្រភេទឯកសារនៅក្នុងប្រភេទ A1-A5 ដែលឯកសារទាំងនោះត្រូវបានជំទាស់ និងកំណត់ពីមូលដ្ឋាននៃការជំទាស់ទាំងនេះ។

ការបែងចែកពេលវេលាសម្រាប់សវនាការលើការជំទាស់ និងការឆ្លើយតបដែលពាក់ព័ន្ធទាំងអស់ មានដូចតទៅនេះ៖

<u>ថ្ងៃ អង្គារ៍ ទី ១៧ ខែ មករា ឆ្នាំ ២០១២</u>

*ឯកសារនៅក្នុងប្រភេទ A1:* រយៈពេល ២ម៉ោង ទុកសម្រាប់ឲ្យក្រុមមេធាវីការពារក្តីទាំងអស់ ធ្វើបទបង្ហាញរាល់ការជំទាស់ ចំពោះប្រភេទឯកសារនេះ (ការបែងចែកពេលវេលា

ជាក់លាក់ ដែលនឹងត្រូវផ្តល់ជូនក្រុមមេធាវីនីមួយៗ ដោយមានការព្រមព្រៀងពីសំណាក់ក្រុមមេធាវីការពារក្តីទាំងអស់)។ បន្ទាប់មកសហព្រះរាជអាជ្ញា មានរយៈពេលមួយម៉ោង និង សហមេធាវីនាំមុខ មានរយៈពេល៣០នាទី ដើម្បីឆ្លើយតប។

*ឯកសារនៅក្នុងប្រភេទ A2:* រយៈពេល ១ម៉ោង ទុកសម្រាប់ឱ្យក្រុមមេធាវីការពារក្តីទាំងអស់ ធ្វើបទបង្ហាញរាល់ការជំទាស់ ចំពោះប្រភេទឯកសារនេះ (ការបែងចែកពេលវេលាជាក់លាក់ ដែលនឹងត្រូវផ្តល់ជូនក្រុមមេធាវីនីមួយៗ ដោយមានការព្រមព្រៀងពីសំណាក់ក្រុមមេធាវីការពារក្តីទាំងអស់)។ បន្ទាប់មកសហព្រះរាជអាជ្ញា មានរយៈពេល៤៥នាទី និង សហមេធាវីនាំមុខ មានរយៈពេល១៥នាទី ដើម្បីឆ្លើយតប។

<u>ថ្ងៃ ពុធ ទី ១៨ ខែ មករា ឆ្នាំ ២០១២</u>

*ឯកសារនៅក្នុងប្រភេទ A3:* រយៈពេល ១ម៉ោង ទុកសម្រាប់ឱ្យក្រុមមេធាវីការពារក្តីទាំងអស់ ធ្វើបទបង្ហាញរាល់ការជំទាស់ ចំពោះប្រភេទឯកសារនេះ (ការបែងចែកពេលវេលាជាក់លាក់ ដែលនឹងត្រូវផ្តល់ជូនក្រុមមេធាវីនីមួយៗ ដោយមានការព្រមព្រៀងពីសំណាក់ក្រុមមេធាវីការពារក្តីទាំងអស់)។ បន្ទាប់មកសហព្រះរាជអាជ្ញា មានរយៈពេល៤៥នាទី និង សហមេធាវីនាំមុខ មានរយៈពេល១៥នាទី ដើម្បីឆ្លើយតប។

*ឯកសារនៅក្នុងប្រភេទ A4:* រយៈពេល ២ម៉ោង ទុកសម្រាប់ឱ្យក្រុមមេធាវីការពារក្តីទាំងអស់ ធ្វើបទបង្ហាញរាល់ការជំទាស់ ចំពោះប្រភេទឯកសារនេះ (ការបែងចែកពេលវេលាជាក់លាក់ ដែលនឹងត្រូវផ្តល់ជូនក្រុមមេធាវីនីមួយៗ ដោយមានការព្រមព្រៀងពីសំណាក់ក្រុមមេធាវីការពារក្តីទាំងអស់)។ បន្ទាប់មកសហព្រះរាជអាជ្ញា មានរយៈពេលមួយម៉ោង និង សហមេធាវីនាំមុខ មានរយៈពេល៣០នាទី ដើម្បីឆ្លើយតប។

<u>ថ្ងៃ ព្រហស្បតិ៍ ទី ១៩ ខែ មករា ឆ្នាំ ២០១២</u>

*ឯកសារនៅក្នុងប្រភេទ A5:* រយៈពេល ២ម៉ោង ទុកសម្រាប់ឱ្យក្រុមមេធាវីការពារក្តីទាំងអស់ ធ្វើបទបង្ហាញរាល់ការជំទាស់ ចំពោះប្រភេទឯកសារនេះ (ការបែងចែកពេលវេលា

ជាក់លាក់ ដែលនឹងត្រូវផ្តល់ជូនក្រុមមេធាវីនីមួយៗ ដោយមានការព្រមព្រៀងពីសំណាក់ក្រុមមេធាវីការពារក្តីទាំងអស់)។ បន្ទាប់មកសហព្រះរាជអាជ្ញា មានរយៈពេលមួយម៉ោង និងសហមេធាវីនាំមុខ មានរយៈពេល៣០នាទី ដើម្បីឆ្លើយតប។

នាពេលបញ្ចប់សវនាការនេះ ក្រុមមេធាវីការពារក្តី ត្រូវបានអនុញ្ញាតឱ្យមានរយៈពេលមួយម៉ោង សម្រាប់សិទ្ធិក្នុងការឆ្លើយតប (ការបែងចែកពេលវេលាជាក់លាក់ ដែលនឹងត្រូវផ្តល់ជូនក្រុមមេធាវីនីមួយៗ ដោយមានការព្រមព្រៀងពីសំណាក់ក្រុមមេធាវីការពារក្តីទាំងអស់) ពាក់ព័ន្ធទៅនឹងរាល់ការជំទាស់ទាក់ទងនឹងប្រភេទឯកសារពី A1-A5។

នៅពេលដែលសវនាការទាំងនេះលើកឡើងអំពីប្រភព ភាពជឿជាក់ និងការរក្សាទុក ឯកសារដែលពាក់ព័ន្ធទៅនឹងឯកសារខាងលើនោះ អង្គជំនុំជម្រះនឹងកោះហៅ និងស្តាប់សក្ខីកម្មសាក្សីមួយចំនួន[4]។ ការស្តាប់សក្ខីកម្មនេះអាចធ្វើឡើងនៅក្នុងសវនាការថ្ងៃទី ១៦ ដល់ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២ ឬនៅពេលបន្ទាប់ពីនេះ។

*ឯកសារបន្ថែមពាក់ព័ន្ធនឹងសវនាការ*

៩. ទស្សីករណ៍ផ្ទាល់មាត់បន្ថែម នឹងត្រូវប្រព្រឹត្តទៅនា ខែ កុម្ភៈ ឆ្នាំ ២០១២ ក្នុងចំណោមឯកសារផ្សេងៗទៀត ពាក់ព័ន្ធនឹងប្រភេទឯកសារទាំងឡាយខាងលើ ដែលមិនបានពិចារណា ក្នុងអំឡុង

---

[4] សូមមើលសំណើរបស់សហព្រះរាជអាជ្ញាដែលបានដាក់ស្របតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងបញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងឧបសម្ព័ន្ធសម្ងាត់ ១,២,៣,៣ក,៤ និង៥ ឯកសារលេខ E9/4 ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ កថាខណ្ឌ ១១ (សហព្រះរាជអាជ្ញាទទួលស្គាល់ភាពចាំបាច់ក្នុងការកោះហៅសាក្សីដើម្បីបញ្ជាក់ពីយថាភាពនៃឯកសារ ដោយបានផ្តល់បញ្ជីឈ្មោះបុគ្គលមួយចំនួននៅក្នុងឧបសម្ព័ន្ធទី ៥)។ សូមមើលផងដែរ ឧបសម្ព័ន្ធទី ៣៖ បញ្ជីឈ្មោះសាក្សី ឯកសារ E9/4.3 ([redacted] គឺជាសាក្សីសក្ខានុពលមួយរូប) និងឧបសម្ព័ន្ធទី ៥ ឯកសារ E9/4.5 ([redacted] គឺជាសាក្សីសក្ខានុពលមួយរូប)។ អង្គជំនុំជម្រះអាចកោះហៅសាក្សី [redacted] និង/ឬ [redacted] ធ្វើជាសាក្សីនៅក្នុងដែនកំណត់មួយជាក់លាក់ពាក់ព័ន្ធនឹងយថាភាពនៃឯកសារនានា។

00767052

ពេលសវនាការពីថ្ងៃទី ១៦ ដល់ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២ ព្រមទាំងឯកសារផ្សេងៗទៀតរបស់ភាគីស្នើឱ្យទទួលយក នៅចំពោះមុខអង្គជំនុំជម្រះ ពាក់ព័ន្ធទៅនឹងដំណាក់កាលសវនាការខាងដើម។ ព័ត៌មានបន្ថែមពាក់ព័ន្ធទៅនឹងសវនាការទាំងនេះនឹងផ្តល់ជូនក្នុងពេលវេលាមួយសមស្រប។